ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣៣៛៣៣

ក្រសួងធនធានទឹក និងឧតុនិយម
លេខ ៧០៤ ធទឧ

ថ្ងៃ សុក្រ ០២កើត ខែ ពិសាខ ឆ្នាំ ជូត ទោ ស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ.ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០២០.

**រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម**
**សូមជម្រាបជូន**
**ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលគ្រប់រាជធានី-ខេត្ត**

**កម្មវត្ថុ ៖** សំណើសុំជួយទប់ស្កាត់ការរំលោភ ចាក់ដីលុបចំណីមាត់ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ អាងទឹក បឹងបួ ។

**យោង ៖** អនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ ស្តីពីការគ្រប់គ្រងអាងទន្លេ

តបតាមកម្មវត្ថុ និងឯកសារយោងខាងលើ សូមជម្រាបឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលគ្រប់រាជធានី-ខេត្ត ជ្រាបថា យោងតាមស្ថានភាពសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជាមានការរីកចម្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានធ្វើឲ្យមានកំណើននៃការសាងសង់គួរឲ្យកត់សម្គាល់ ។ ទន្ទឹមនឹងការរីកចម្រើននេះ យើងក៏សង្កេតឃើញមានសកម្មភាពអវិជ្ជមានមួយចំនួន ដូចជាការរំលោភ ចាក់ដីលុបចំណីមាត់ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ អាងទឹក បឹងបួ ដែលជាសម្បត្តិសាធារណៈរបស់រដ្ឋ ។

ផ្តើមចេញពីសកម្មភាពខាងលើនេះ ក្រសួងធនធានទឹក និងឧតុនិយមមានការព្រួយបារម្ភជាខ្លាំងចំពោះបញ្ហាដែលអាចកើតឡើងដល់លទ្ធភាពនៃការរំដោះទឹក និងបង្កជាគ្រោះមហន្តរាយទឹកជំនន់ដោយសារចំណីមាត់ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ អាងទឹក បឹងបួ ឬតំបន់ផ្ទៃរងទឹកភ្លៀងមួយចំនួនត្រូវបានរំលោភ ចាក់ដីលុប និងការសាងសង់បិទផ្លូវទឹកនានា ដោយពុំស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលគ្រប់រាជធានី-ខេត្ត ជ្រាប និងមានវិធានការសមស្រប ដើម្បីជួយទប់ស្កាត់ការរំលោភ ចាក់ដីលុបចំណីមាត់ច្រាំងទន្លេ ស្ទឹង ព្រែក អូរ ប្រឡាយ អាងទឹក បឹងបួ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្តបានកំណត់ ។

សូមឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលគ្រប់រាជធានី-ខេត្ត ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម
- អគ្គនាយកក្រសួង
- អគ្គាធិការ
- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- មន្ទីរធនធានទឹក និងឧតុនិយមគ្រប់រាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

រដ្ឋមន្ត្រី

**លឹម_គានហោ**

• អគារលេខ: ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១៦ ៦៧០
# 364 Monivong BLVD, Phsar Deumthkov, Chamkarmon, Phnom Penh, Cambodia, Phone: (855)23 216 670